# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ៤

LECTURE 4

## សន្ធិសញ្ញា (ត)

TREATY (CONTINUE)

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្ដីផ្ដើម
- ផ្នែកទី២ លក្ខខណ្ឌសុពលភាពនៃសន្ធិសញ្ញា
    - លក្ខខណ្ឌគ្រឹះនៃសុពលភាព
    - វិការៈនៃការព្រមព្រៀង
- ផ្នែកទី៣ អានុភាពគតិយុត្តនៃសន្ធិសញ្ញា
    - អានុភាពចំពោះរដ្ឋភាគី
    - អនុភាពចំពោះរដ្ឋតតីភាគី
- ផ្នែកទី៤ ការផុតរលត់នៃសន្ធិសញ្ញា
    - ការផុតរលត់តាមឆន្ទៈរបស់ភាគី
    - ការផុតរលត់ក្រៅឆន្ទៈរបស់ភាគី

# កម្មវត្ថុនៃមេរៀន

មេរៀនស្តីអំពី សន្និសញ្ញាមានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពីៈ

- អ្វីទៅជាសន្និសញ្ញា
- តើសន្និសញ្ញាមានធាតុផ្សំអ្វីខ្លះ?
- សន្និសញ្ញាមានលក្ខខណ្ឌសុពលភាពអ្វីខ្លះ?
- តើសន្និសញ្ញាត្រូវគោរពនូវលក្ខខណ្ឌអ្វីខ្លះ
- យល់ដឹងពីខដាក់លក្ខខណ្ឌនៃសន្និសញ្ញា
- ស្វែងយល់ពីគុណសម្បត្តិ និងគុណវិប្បត្តិនៃខដាក់លក្ខខណ្ឌ
- យល់ពីអត្ថប្រយោជន៍នៃសន្និសញ្ញា

# ផ្នែកទី១ សេចក្តីផ្តើម

យើងបានសិក្សារួចហើយនូវផ្នែកខ្លះនៃសន្និសញ្ញា រួមមានដូចជា សញ្ញាណទូទៅ ធាតុផ្សំនៃសន្និសញ្ញា និងលក្ខខណ្ឌសុពលភាពនៃសន្និសញ្ញា (លក្ខខណ្ឌទម្រង់នៃសុពលភាពនៃសន្និសញ្ញា)។ ហើយនៅក្នុងមេរៀនទី៥នេះ យើងនឹងញធ្វើការសិក្សាពីលក្ខខណ្ឌសុពលភាពនៃសន្និសញ្ញា (លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្និសញ្ញា) អានុភាពនៃសន្និសញ្ញា និងការផុតរលត់នៃសន្និសញ្ញា។

# ផ្នែកទី១ សេចក្តីផ្តើម

មិនខុសពីកិច្ចសន្យានៃការរស់នៅប្រចាំថ្ងៃនោះទេ សន្និសញ្ញាត្រូវបំពេញនូវលក្ខខណ្ឌចម្បងចំនួនពីរគឺ លក្ខខណ្ឌទម្រង់នៃសុពលភាព (ផ្នែកទី៤ នៃមេរៀនទី៣) និងលក្ខខណ្ឌគ្រឹះនៃសុពលភាព ដែលយើងនឹងត្រូវសិក្សានៅក្នុងមេរៀនទី៤នេះ។

# ផ្នែកទី២ លក្ខខណ្ឌសុពលភាពនៃសន្ធិសញ្ញា

- លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា

លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា គឺសំដៅធានានូវភាពស្របច្បាប់នៃសន្ធិសញ្ញា ជាពិសេសទាក់ទងភាពស្របច្បាប់នៃកម្មវត្ថុ និងភាពស្របច្បាប់នៃការផ្តល់ការយល់ព្រមរបស់ភាគី។

# លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា

- វិការៈនៃការព្រមព្រៀង

ប្រសិនបើភាគីណាមួយរកឃើញថា សន្ធិសញ្ញាដែលបានបង្កើតឡើងនោះមានវិការៈ ដែលផ្ទុយទៅនិងឆន្ទៈពិតរបស់ភាគី នាំឲ្យសន្ធិសញ្ញាដែលបានបង្កើតឡើងត្រូវបាត់បង់នូវសុពលភាពគតិយុត្តរបស់វា។ វិការៈនៃការព្រមព្រៀងមានដូចជា ការបង្ខំ ការភាន់ច្រឡំ និងការល្បួចបន្លំ។

# លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា

- វិការៈនៃការព្រមព្រៀង
  - ការបង្ខំ គឺជាសកម្មភាពហិង្សា ឬបៀតបៀនដែលនាំឲ្យប៉ះពាល់សុពលភាពគតិយុត្តនៃសន្ធិសញ្ញា។ ការបង្ខំអាចកើតឡើងទៅលើរដ្ឋ និងអាចកើតឡើងទៅលើអ្នកតំណាងរបស់រដ្ឋ។

# លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា

- វិការៈនៃការព្រមព្រៀង
  - ការបង្ខំទៅលើរដ្ឋ ជាសកម្មភាពគំរាមកំហែង ឬ សកម្មភាពនៃការប្រើប្រាស់កម្លាំងរបស់ភាគីណាមួយ នាំឲ្យបំពានទៅដល់គោលការណ៍ នៃការបង្ហាញឆន្ទៈពិតរបស់ភាគីម្ខាងទៀត ដែលត្រូវបានធានាដោយធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

# លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា

- ការបង្ខំទៅលើរដ្ឋ

ឧទាហរណ៍ លក្ខន្តិកៈរបស់ទីក្រុងហុងកុង និងម៉ាកាវត្រូវបានធ្វើការសើរើតាមរយៈកិច្ចព្រមព្រៀងឆ្នាំ១៩៨៤ និង កិច្ចព្រមព្រៀងឆ្នាំ១៩៨៧ ដើម្បីប្រគល់ដែនដីហុងកុងទៅឲ្យប្រទេសចិននៅឆ្នាំ១៩៩៧ និងដែនដីម៉ាកាវនៅឆ្នាំ ១៩៩៩។

# លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា

- វិការៈនៃការព្រមព្រៀង
  - ការបង្ខំទៅលើអ្នកតំណាងរបស់រដ្ឋ ជាសកម្មភាពកើតឡើងដោយផ្ទាល់ទៅលើបុគ្គលដែលជាអ្នកតំណាងរបស់រដ្ឋដែលជាភាគីក្នុងពេលទៅចូលរួមចរចារ ឬ ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ឬ សន្ធិសញ្ញាអន្តរជាតិណាមួយ។ សកម្មភាពនាំប៉ះពាល់ដល់សុពលភាពគតិយុត្តនៃសន្ធិសញ្ញានោះ។

# លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា

- វិការៈនៃការព្រមព្រៀង
  - ការបង្ខំទៅលើអ្នកតំណាងរបស់រដ្ឋ អាចកើតឡើងតាមរូបភាព ជាការធ្វើទារុណកម្មលើរូបរាងកាយរបស់អ្នកតំណាងឬអាចជាការធ្វើទារុណកម្មផ្នែកផ្លូវចិត្តរបស់អ្នកតំណាង។ ដូច្នេះហើយបានជាការផ្តល់សច្ចាប័ន គឺជានីតិវិធីមួយជួយធានាដើម្បីជៀសវាងការធ្វើមោឃភាពនៃសន្ធិសញ្ញា ដោយអំពើខុសច្បាប់នេះ។

# លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា

- វិការៈនៃការព្រមព្រៀង
  - ការភាន់ច្រឡំ គឺជាសកម្មភាពដែលភាគីច្រឡំអំពីហេតុការ ឬ ព្រឹត្តិការណាមួយថាកើតឡើង ឬ មិនកើតឡើងដែលជាមូលហេតុក្នុងការផ្តល់ការព្រមព្រៀង។ ការភាន់ច្រឡំទៅលើអង្គច្បាប់ មិនអាចយកមកធ្វើជាមូលហេតុក្នុងការទាមដើម្បីលុបចោលសន្ធិសញ្ញាបានឡើយ។

# លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្និសញ្ញា

- វិការៈនៃការព្រមព្រៀង
  - ការភាន់ច្រឡំ ដើម្បីអាចទាមទារឲ្យរំលាយសន្និសញ្ញាបាន លុះណាគោរពនូវលក្ខខណ្ឌដូចខាងក្រោម៖

ក. ការភាន់ច្រឡំ ត្រូវតែជាការភាន់ច្រឡំទៅលើហេតុការណ៍ ឬស្ថានភាព ដែលភាគីចាត់ទុកថាមានពិតប្រាកដនៅពេលដែលខ្លួនផ្តល់ការព្រមព្រៀង (រឿងក្តីប្រាសាទព្រះវិហារ)។

# លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា

- វិការៈនៃការព្រមព្រៀង
  - ការភាន់ច្រឡំ

ខ. ការភាន់ច្រឡំនោះត្រូវបានចាត់ទុកថាមានសភាពធ្ងន់ធ្ងរ។

គ. រដ្ឋរងគ្រោះ ពុំមានសកម្មភាពណាមួយចូលរួមជាមួយការភាន់ច្រឡំឡើយ។ ប្រសិនបើខ្លួនដឹងថាមានការភាន់ច្រឡំរដ្ឋនោះត្រូវជូនដំណឹងទៅភាគីដែលពាក់ព័ន្ធ។

# លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា

- វិការៈនៃការព្រមព្រៀង
  - ការល្អចបន្លំ គឺជាសកម្មភាពនៃការប្រើល្បិចកលដើម្បីឲ្យភាគីម្ខាងទៀត ផ្តល់នូវការព្រមព្រៀងរបស់នៅក្នុងសន្ធិសញ្ញាណាមួយដែលផ្ទុយពីឆន្ទៈពិតរបស់ខ្លួនទៅលើហេតុការណ៍ ឬក៏ទៅលើព្រឹត្តិការណ៍ណាមួយដែលមិនពិត តែភាគីយល់ថាវាគឺជាការពិត ឬការពិតតែខ្លួនយល់ថាមិនពិតទៅវិញ។

# លក្ខខណ្ឌគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា

- វិការៈនៃការព្រមព្រៀង
  - ការលួចបន្លំ គេមិនដែលឃើញមាននូវសកម្មភាពនៃការលួចបន្លំកើតឡើងនោះឡើយ នោះក៏ដោយសារតែរដ្ឋជាភាគីមុននឹងផ្តល់ការព្រមព្រៀងរបស់ខ្លួន ចំពោះសន្ធិសញ្ញាណាមួយគឺបានធ្វើការត្រួតពិនិត្យជាច្រើនដំណាក់កាល។ ឧទាហរណ៍ករណីប្រទេសកម្ពុជា មុននឹងថ្វាយព្រះប្រមុខរដ្ឋទ្រង់ឡាយព្រហស្សលេខា ត្រូវទទួលការយល់ព្រមពីសភាទាំងពីរថ្នាក់សិន។

# លក្ខណៈគ្រឹះនៃសុពលភាពនៃសន្ធិសញ្ញា

- វិការៈនៃការព្រមព្រៀង
  - អំពើពុករលួយ មាត្រា៥០ អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩ បានលើកឡើង ទាក់ទង់ទៅនឹងការផ្តល់ការព្រមព្រៀងរបស់ខ្លួន កើតឡើងដោយសារមានអំពើពុករលួយទៅលើអ្នកតំណាងរបស់រដ្ឋ ទោះបីដោយផ្ទាល់ ឬ ដោយប្រយោលក៏ដោយ។ នោះរដ្ឋអាចលើកយកមូលហេតុនេះដើម្បីលុបចោលសន្ធិសញ្ញាដែលបានផ្តល់ការព្រមព្រៀងនោះបាន។

# ផ្នែកទី៣ អានុភាពគតិយុត្តនៃសន្ធិសញ្ញា

ជាទូទៅសន្ធិសញ្ញា មានអនុភាពគតិយុត្តចំពោះតែភាគីរបស់វាតែប៉ុណ្ណោះ លើកលែងសន្ធិសញ្ញាសត្យានុម័តមួយចំនួន។ សន្ធិសញ្ញាមានអានុភាពពីរយ៉ាង គឺអានុភាពចំពោះរដ្ឋដែលជាភាគី និងអានុភាពចំពោះរដ្ឋដែលមិនមែនជាភាគី។ តទៅនេះយើងនឹងធ្វើការសិក្សាទៅលើអានុភាពទាំងពីរនេះ។

# ផ្នែកទី៣ អានុភាពគតិយុត្តនៃសន្ធិសញ្ញា

- អានុភាពចំពោះរដ្ឋដែលជាភាគី

រដ្ឋដែលជាភាគីនៃសន្ធិសញ្ញា ត្រូវអនុវត្តសន្ធិសញ្ញាដោយឈរលើគោលការណ៍សុចរិតស្មោះត្រង់ PACTA SUNT SERVANDA គឺគ្រប់សន្ធិសញ្ញាដែលបានចូលជាធរមានចំពោះរដ្ឋដែលជាភាគីទាំងអស់ ហើយរដ្ឋដែលជាភាគីត្រូវអនុវត្តសន្ធិសញ្ញានោះក្នុងគោលបំណងល្អ។

# ផ្នែកទី៣ អានុភាពគតិយុត្តនៃសន្ធិសញ្ញា

- អានុភាពចំពោះរដ្ឋដែលជាភាគី

បើទោះជាមានការប្រែប្រួល ឬ មាការផ្លាស់ប្តូរក្បាលម៉ាស៊ីនដឹកនាំរដ្ឋដែលបានចុះកិច្ចព្រមព្រៀងក៏ដោយ ក៏សន្ធិសញ្ញានោះ នៅតែមានអានុភាពចំពោះរដ្ឋដែលជាភាគីនោះដដែលនេះដោយឈរលើគោលការណ៍និរន្តរភាពរដ្ឋ។

# ផ្នែកទី៣ អានុភាពគតិយុត្តនៃសន្ធិសញ្ញា

- អានុភាពចំពោះរដ្ឋដែលជាភាគី

ជាទូទៅ រដ្ឋមិនអាចធ្វើការអះអាងពីច្បាប់ផ្ទៃក្នុងរបស់ខ្លួន ដើម្បីជាមូលហេតុមិនអនុវត្តសន្ធិសញ្ញាបានឡើយ។ មាត្រា ២៧ អនុសញ្ញាទីក្រុងវីយែន ចែងថា រដ្ឋដែលជាភាគីមិនអាច លើកយកច្បាប់ផ្ទៃក្នុងរបស់ខ្លួនមកធ្វើការអះអាង ដើម្បីជាលេះមិនអនុវត្តសន្ធិសញ្ញាបានឡើយ។

# ផ្នែកទី៣ អានុភាពគតិយុត្តនៃសន្ធិសញ្ញា

- អានុភាពចំពោះភាគីនៃសន្ធិសញ្ញា

សន្ធិសញ្ញាអន្តរជាតិ  មិនបង្កើតឲ្យមានអានុភាពគតិយុត្ត ដោយផ្ទាល់ចំពោះបុគ្គលឯកជននោះឡើយ  តែអានុភាព នេះអាចកើតឡើងតាមរយៈច្បាប់ផ្ទៃក្នុងរបស់រដ្ឋ ដែលជា ភាគី។

# ផ្នែកទី៣ អានុភាពគតិយុត្តនៃសន្ធិសញ្ញា

- អានុភាពចំពោះភាគីនៃសន្ធិសញ្ញា

ក្នុងករណីដែលទាក់ទងទៅនិងបញ្ហាសិទ្ធិមនុស្ស ឬ បញ្ហាដែលទាក់ទងនិងជនភៀសខ្លួន បុគ្គលអាចលើកយកមកសម្អាងបាន។ ជាទូទៅ សន្ធិសញ្ញាមិនបង្កើតឲ្យមានអានុភាពប្រតិសកម្មឡើយដូចដែលមានចែងនៅក្នុងមាត្រា ២៨ អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៩។

# ផ្នែកទី៣ អានុភាពគតិយុត្តនៃសន្ធិសញ្ញា

- អានុភាពចំពោះភាគីនៃសន្ធិសញ្ញា

ជាធម្មតាសន្ធិសញ្ញាបង្កើតឲ្យមានអានុភាពគតិយុត្ត ទោះលើដែនដីទាំងមូលរបស់រដ្ឋ លើកលែងតែភាគីប្រាថ្នាចង់បានក្រៅពីនេះ ហើយដែលមានបញ្ជាក់នៅក្នុងសន្ធិសញ្ញា។ ក្នុងករណីដែលដែនដីនៅឯនាយសមុទ្រ គឺត្រូវអនុវត្តទៅតាមអ្វីដែលមានចែងនៅក្នុងខដែនដីនៃសន្ធិសញ្ញា។

# ផ្នែកទី៣ អានុភាពគតិយុត្តនៃសន្ធិសញ្ញា

- ដែនកំណត់នៃអានុភាពនៃសន្ធិសញ្ញា

ក្នុងករណីនេះ រដ្ឋដែលជាភាគីអាចលើកឡើងនូវមូលហេតុមួយចំនួនដើម្បីរួចផុតពីការទទួលខុសត្រូវ ដែលករណីទាំងនោះរួមមានដូចជា ករណីប្រធានសក្តិ ការការពារខ្លួនជាធម្មានុរូប និងការលើកឡើងពីផលប្រយោជន៍ជាសារវន្តរបស់រដ្ឋ។

# ផ្នែកទី៣ អានុភាពគតិយុត្តនៃសន្ធិសញ្ញា

- អានុភាពចំពោះតតិយភាគីនៃសន្ធិសញ្ញា

ជាទូទៅ សន្ធិសញ្ញាមិនបង្កើតការបង្ខំណាមួយ ចំពោះរដ្ឋណាមួយដែលមិនបានទទួលយកវាឡើយ។ ប៉ុន្តែលក្ខខណ្ឌនេះអាចទទួលការលើកលែងមួយចំនួនដូចជា តតិយភាគីទទួលបាននូវសិទ្ធិដែលជាប្រយោជន៍ដោយស្វ័យប្រវត្តិ ឧទាហរណ៍សន្ធិសញ្ញាស្តីពីផ្លូវគមនាគមន៍អន្តរជាតិ ជាអាទ៍។

# ផ្នែកទី៣ អានុភាពតតិយជននៃសន្ធិសញ្ញា

- អានុភាពចំពោះតតិយភាគីនៃសន្ធិសញ្ញា

សន្ធិសញ្ញាសត្យានុម័តមួយចំនួន បានបង្កើតឲ្យមានការបង្ខំចំពោះរដ្ឋដែលជាតតិយភាគី ដោយពុំចាំបាច់ផ្តល់នូវការយល់ព្រមរបស់ខ្លួននោះឡើយ ឧទាហរណ៍សន្ធិសញ្ញាស្តីពីលក្ខន្តិកៈដែនដី និងសន្ធិសញ្ញាស្តីពីអព្យាក្រឹតភាព ជាអាទិ៍។

# ផ្នែកទី៤ ការផុតរលត់នៃសន្ធិសញ្ញា

ការផុតរលត់នៃសន្ធិសញ្ញា គឺជាការបញ្ចប់នូវអានុភាពទាំងស្រុងនៃសន្ធិសញ្ញា ដែលខុសពីការពន្យាពេលនៃការអនុវត្តឡើយ។ ការពន្យាពេលនៃការអនុវត្ត គឺជាការចញ្ចាប់នូវអានុភាពគតិយុត្តនៃសន្ធិសញ្ញាតែក្នុងរយៈពេលណាមួយជាក់លាក់តែប៉ុណ្ណោះ។

# ផ្នែកទី៤ ការផុតរលត់នៃសន្ធិសញ្ញា

- ការផុតរលត់តាមឆន្ទៈរបស់ភាគី

រដ្ឋដែលជាភាគី អាចព្រមព្រៀងគ្នាជាមុនដើម្បីបញ្ចប់នូវអានុភាពគតិយុត្តនៃសន្ធិសញ្ញាជាមុន ដែលក្នុងនោះអាចមាន សន្ធិសញ្ញាដែលបង្កើតឡើងសម្រាបើរយៈពេលជាក់លាក់ សន្ធិសញ្ញាសម្រាប់ការបំពេញកាតព្វកិច្ចណាមួយ សន្ធិសញ្ញាដែលកំណត់ពីលក្ខខណ្ឌក្នុងការបញ្ចប់អានុភាព។

# ផ្នែកទី៤ ការផុតរលត់នៃសន្ធិសញ្ញា

- ការផុតរលត់តាមឆន្ទៈរបស់ភាគី

សន្ធិសញ្ញាដែលភាគីបានធ្វើការប្រកាសដកខ្លួន មានចំនួនច្រើនជាងចំនួនកំណត់ឲ្យវាចូលជាធរមាន និងសន្ធិសញ្ញាដែលរដ្ឋជាភាគី បានព្រមព្រៀងគ្នាថាបញ្ចប់អានុភាពរបស់វាដូចជាករណីសង្គមប្រជាជាតិ ជាដើម។

# ផ្នែកទី៤ ការផុតរលត់នៃសន្និសញ្ញា

- ការផុតរលត់ក្រៅឆន្ទៈរបស់ភាគី

សន្និសញ្ញាអាចត្រូវផុតរលត់លែងមានអានុភាព ដោយសារមានព្រឹត្តិការក្រៅឆន្ទៈរបស់ភាគីកើតឡើង។ ព្រឹត្តិការទាំងនោះអាចមានដូចខាងក្រោម៖

ក. ការកើតឡើនូវបទដ្ឋានអាជ្ញាបញ្ញាថ្មី គឺសន្និសញ្ញានោះអាចនឹងត្រូវផុតរលត់ ប្រសិនបើសន្និសញ្ញានោះផ្ទុយទៅនឹងបទដ្ឋានអាជ្ញាបញ្ញាថ្មីនោះ។

# ផ្នែកទី៤ ការផុតរលត់នៃសន្ធិសញ្ញា

- ការផុតរលត់ក្រៅឆន្ទៈរបស់ភាគី

ខ. សន្ធិសញ្ញាអាចនឹងត្រូវផុតរលត់ផងដែរ ប្រសិនបើមានការប្រែប្រួលកម្មវត្ថុនៃសន្ធិសញ្ញា ឬ ក្នុងករណីមានការកែប្រែលក្ខន្តិកៈរបស់រដ្ឋ ឧទាហរណ៍សន្ធិសញ្ញាដែលចែងអំពីការជួលដី នៅពេលដែលស្ថានភាពដីនោះមានការដែប្រែ សន្ធិសញ្ញានោះក៏ត្រូវប្រែប្រួលស្ថានភាពគតិយុត្តដែរ។

# ផ្នែកទី៤ ការផុតរលត់នៃសន្ធិសញ្ញា

- ការផុតរលត់ក្រៅឆន្ទៈរបស់ភាគី

គ. ក្នុងករណីដែលមានរដ្ឋណាមួយ ដែលជាភាគីនៃសន្ធិសញ្ញាបានរំលោភបំពានលើបញ្ញត្តិជាសារវ័ន្ត នៃសន្ធិសញ្ញានោះសន្ធិសញ្ញានឹងត្រូវផុតរលត់ផងដែរ។ ប៉ុន្តែ អញ្ញត្រកម្មនេះមិនអាចយកមកអនុវត្តបានឡើយ ចំពោះសន្ធិសញ្ញាស្តីពីមនុស្សធម៌។

មេរៀនទី៩ ស្ដីពីសន្និសញ្ញា(ត) ត្រូវបានបញ្ចប់ សូមអរគុណសម្រាប់ការតាមដានដោយយកចិត្តទុកដាក់ ពីសំណាក់អ្នកសិក្សាទាំងឡាយ។